01105560

E348/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 06 / 2015
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម យូរ ឧត្តរា |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និង ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និង ស្នើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271) ជាមួយនឹងសាក្សី ស្រី ថន (2-TCW-944) និង ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង (2-TCCP-304) និង ស្នើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន[1]។

២. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មពីថ្ងៃទី ០៤ ដល់ទី ០៦ ខែ កុម្ភៈ និង ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥[2]។ សាក្សី ស្រី ថន បានផ្តល់សក្ខីកម្មកាលពីថ្ងៃទី ១៩ ទី ២៣ និង ទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥[3] ហើយដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មនៅថ្ងៃទី ២៤ និង ទី ២៥ ខែ មីនា ឆ្នាំ ២០១៥[4]។

## ២. សារណា

៣. មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម សយ សែន ដែលបានកំណត់អត្តសញ្ញាណខ្លួនគាត់ថាជាអតីតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់ បានធ្វើការចោទប្រកាន់ផ្សេងៗចំពោះ សូត្រ សាំង និង ស្រី ថន ដែលជាអតីតបុគ្គលិកមន្ទីរសន្តិសុខនោះ[5]។ ការចោទប្រកាន់ទាំងនេះរួមមាន (១) ការទទួលខុសត្រូវរបស់ សូត្រ សាំង និង ស្រី ថន ចំពោះការ

---

[1] "សំណើសុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និង ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និង ស្នើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត" ("សំណើ") ឯកសារ E348 ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥។ បន្ទាប់ពីមានការលើកឡើងដោយផ្ទាល់មាត់អំពីសំណើនេះកាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យមេធាវីការពារក្តី ខៀវ សំផន ដាក់សារណាជាលាយលក្ខណ៍អក្សរ។ (សូមមើល ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ៨៨-៩១)។

[2] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥, ប្រតិចារឹក ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥, ប្រតិចារឹក ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥, ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥។

[3] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥, ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ និង ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[4] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៥, ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥។

[5] សំណើសុំ កថាខណ្ឌ ២។

សម្លាប់ក្មេងពីរនាក់ (២) ការប្រព្រឹត្តិការរំលោភផ្លូវភេទដោយ សួត្រ សាំង និង ស្រី ថន ចំពោះអ្នកជាប់ឃុំស្ត្រីពីរនាក់ និង ការសម្លាប់ស្ត្រីទាំងពីរនាក់នោះ នាពេលក្រោយមកទៀត (៣) ភាពសាហាវយង់ឃ្នងរបស់ សួត្រ សាំង និង ស្រី ថន (៤) ការព្យាយាមរំខានដល់ការផ្តល់សក្ខីកម្មរបស់ សយ សែន និង (៥) តួនាទីរបស់ សួត្រ សាំង ជាប្រធានកងសន្តិសុខនៅមន្ទីរសន្តិសុខក្រាំងតាចាន់[6]។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា សួត្រ សាំង និង ស្រី ថន បានបដិសេធរហូតនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងចំពោះការចោទប្រកាន់ទាំងប៉ុន្មានខាងលើនេះ[7]។ ហេតុដូច្នេះ អនុលោមតាមវិធាន ៩១ និង ៩៣ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅ សយ សែន សួត្រ សាំង និង ស្រី ថន សាជាថ្មី និង សួរដេញដោលពួកគាត់រួមគ្នា ដើម្បីបញ្ជាក់អំពីបញ្ហាចម្រូងចម្រាស់ផ្សេងៗដែលបានកំណត់នៅក្នុងសំណើសុំខាងលើ[8]។

៤. មេធាវីការពារក្តី ខៀវ សំផន ក៏បានអះអាងបន្ថែមទៀតថា មានបញ្ហានៃភាពអាចជឿទុកចិត្តបានទៅលើ សយ សែន ដោយសារតែភាពខុសគ្នាយ៉ាងខ្លាំងរវាងសក្ខីកម្មដែលគាត់បានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង សក្ខីកម្ម ឬ ចម្លើយពីមុននៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា និង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជាពិសេស ពាក់ព័ន្ធនឹងថាតើអ្នកទោសជាស្ត្រីមួយចំនួនត្រូវបានរំលោភផ្លូវភេទដែរ ឬ ទេនោះ[9]។ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃបានត្រឹមត្រូវអំពីភាពអាចជឿទុកចិត្តបានរបស់ សយ សែន និង ចៀសវាងការរំលោភបំពានទៅលើសិទ្ធិរបស់មេធាវីការពារក្តីនោះ មេធាវីការពារក្តី ខៀវ សំផន ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងយកឯកសារថតសម្លេងនៃការស្តាប់ចម្លើយ សយ សែន ពីការិយាល័យសហចៅក្រមស៊ើបអង្កេត[10]។

៥. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ឱកាសត្រូវបានផ្តល់គ្រប់គ្រាន់រួចហើយទៅដល់ភាគីនានាដើម្បីសួរដេញដោល សយ សែន សួត្រ សាំង និង ស្រី ថន ហើយថា អង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពរួចជាស្រេចហើយក្នុងការវាយតម្លៃទៅលើភាពជឿទុកចិត្ត និង ភាពជឿជាក់បាន

[6] សំណើសុំ កថាខណ្ឌ ៦-១០។

[7] សំណើសុំ កថាខណ្ឌ ២, ៦-១០។

[8] សំណើសុំ កថាខណ្ឌ ៤, ១១, ២០។

[9] សំណើសុំ កថាខណ្ឌ ៣-១៧។ (យោងទៅឯកសារ E3/4846 ទំព័រ ១០-១១ និង ឯកសារ E319.1.24 ទំព័រ ១៤-១៥)។

[10] សំណើសុំ កថាខណ្ឌ ១៩។

ចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងសំណើសុំ[11]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាសន្និដ្ឋានថា បញ្ហាមួយចំនួនមិនមានភាពពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងទៅនឹងជនជាប់ចោទ ឬ ត្រូវបានគ្របដណ្តប់នៅក្នុងសក្ខីកម្ម ឬ ឯកសារដែលបន្សល់ទុកពីសម័យនោះរួចហើយ[12]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការសួរដេញដោលតទល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនៅក្នុងសវនាការទៅលើបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងសំណើនោះនឹង "នាំឱ្យពន្យារពេលការជំនុំជម្រះឥតប្រយោជន៍ ដោយមិនបានចូលរួមចំណែកជាសារវន្តក្នុងការស្វែងរកការពិតឡើយ"[13]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានអះអាងទៀតថា ការអនុញ្ញាតឱ្យទទួលបានឯកសារថតសម្លេងនៃការស្តាប់ចម្លើយ សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនមែនជាការចាំបាច់ទេ ដោយសារភាគីទាំងអស់មានលទ្ធភាពពិនិត្យមើលឯកសារថតសម្លេងទាំងនេះបាន ឬ ក៏ថាមិនអាចធ្វើទៅបានទេដោយសារសំណើសុំនេះរួមមានឯកសារថតសម្លេងដែលមិនមានអត្ថិភាព[14]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបដិសេធសំណើសុំនេះចោល[15]។

៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា "ពុំមានសិទ្ធិក្នុងការតទល់គ្នារវាង ឬ ក្នុងចំណោមសាក្សី និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណីឡើយ"[16] ហើយថា ភាពមិនស៊ីសង្វាក់ណាមួយដែលមាននៅក្នុងភស្តុតាងនោះ នឹងត្រូវតទល់គ្នានៅក្នុងសវនាការនៃការធ្វើសេចក្តីសន្និដ្ឋាន

---

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និង ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និង ស្នើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត" ឯកសារ E348/1 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ៤-៥។

[12] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

[16] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ឯកសារ E348) ឯកសារ E348/2 ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ៧។

បញ្ចប់ការពិភាក្សាដេញដោល[17]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការតទល់គ្នាក្នុងចំណោមសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ទំនងជាមិនអាចជួយអង្គជំនុំជម្រះ ក្នុងការបញ្ជាក់ការពិតឡើយ ហើយក៏អាចប៉ះពាល់ដល់ការសម្រេចគោលបំណងនៃការជំនុំជម្រះក្តីឱ្យបានឆាប់រហ័ស និង ធ្វើឱ្យប៉ះពាល់ដល់ការផ្សះផ្សានៅក្នុងសហគមន៍ថែមទៀត[18]។ ហេតុដូច្នេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យដល់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំឱ្យមានការតទល់គ្នានេះ ហើយទុកឱ្យអង្គជំនុំជម្រះប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោះស្រាយ សំណើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយ សយ សែន[19]។

៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា ពួកគេបានពិគ្រោះយោបល់ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង សូត្រ សាំង។ ជាលទ្ធផល សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា មិនមានទំនាស់ផលប្រយោជន៍រវាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ចូលគ្នាតែមួយនៅក្នុងសំណុំរឿងនេះ ជាមួយនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ សយ សែន និង សូត្រ សាំង ឡើយ[20]។

## ៣. ច្បាប់ជាធរមាន និង សំអាងហេតុ

៨. អង្គជំនុំជម្រះសាលាដំបូងរម្លឹកអំពីឆន្ទានុសិទ្ធិរបស់ខ្លួន អនុលោមតាមវិធាន ៩១ នៃវិធានផ្ទៃក្នុង ក្នុងការស្តាប់ចម្លើយរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ទៅតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធមិនពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក) មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិនសមស្របសម្រាប់

---

[17] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧-៨។

[18] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨-៩។

[19] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១ និង ៥។

[20] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១០។ សារណានេះឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី នួន ជា (សូមមើល អ៊ីមែលរបស់មេធាវីការពារក្តី នួន ជា ផ្ញើទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥) ដើម្បីបញ្ជាក់អំពីបញ្ហាជម្លោះផលប្រយោជន៍ពាក់ព័ន្ធនឹងការធ្វើជាតំណាងផ្លូវច្បាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង សូត្រ សាំង។

បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍[21]។

៩. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា មិនមានបទប្បញ្ញត្តិណាមួយជាក់លាក់ចែងអំពីការតទល់គ្នារវាងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញ នៅក្នុងដំណាក់កាលជំនុំជម្រះឡើយ[22] ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះអាចសម្រេចរៀបចំឱ្យមានការតទល់គ្នារវាងសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលមានហេតុផល និង តម្រូវការចាំបាច់ ទៅតាមកាលៈទេសៈផ្សេងៗ ព្រោះថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិ អនុលោមតាមវិធាន ៨៧(៤) និង វិធាន ៩១ នៃវិធានផ្ទៃក្នុង ក្នុងការចាត់វិធានការណាមួយដែលអាចជួយបញ្ជាក់ការពិតបាន។

១០. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះបីជាការចោទប្រកាន់ធ្ងន់ធ្ងរដោយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញណាម្នាក់ ត្រូវបានច្រានចោល ឬ មានភាពផ្ទុយគ្នាជាមួយនឹងសក្ខីកម្មរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញផ្សេងទៀត ក៏ស្ថានភាពបែបនេះមិនប្រាកដថា តម្រូវឱ្យមានការតទល់គ្នាក្នុងចំណោមពួកគេនោះដែរ ជាពិសេសនៅពេលដែលភាគីទាំងអស់មានឱកាសសួរដេញដោលពួកគេ រួមទាំងការសួរអំពីភាពមិនស៊ីសង្វាក់គ្នា ឬ ភាពខុសគ្នានៅក្នុងចម្លើយរបស់ពួកគេរួចហើយ។

១១. អង្គជំនុំជម្រះកត់សម្គាល់ថា ហេតុការណ៍នៃការរំលោភផ្លូវភេទអាចជាការពាក់ព័ន្ធ ក្នុងចំណោមការពាក់ព័ន្ធផ្សេងទៀត ទៅនឹងលក្ខខណ្ឌនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានច្រានចោលសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមបទចោទស្តីពីការរំលោភ

---

[21] វិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* កាំង ហ្គេកអ៊ាវ ហៅ ឌុច សាលក្រម អង្គជំនុំជម្រះសាលាដំបូង ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១។ *រដ្ឋអាជ្ញា ទល់នឹង Karemera និង អ្នកផ្សេងទៀត* សាលដីកាទៅលើបណ្តឹងឧទ្ធរណ៍របស់ Mathieu Ngirumpatse ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-98-44-AR73.14) ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥ (យល់ឃើញថា លក្ខណៈជាន់គ្នានៃសក្ខីកម្មគឺជាកត្តាដែលត្រូវពិចារណានៅក្នុងការកំណត់ថាតើសវនាការគឺជាការចាំបាច់ដែរ ឬ ទេ)។

[22] ចំពោះការតទល់គ្នាដែលត្រូវសម្រេចដោយសហចៅក្រមស៊ើបអង្កេតនៅដំណាក់កាលមុនសវនាការ សូមមើល វិធាន ៥៨ (៣)-(៤) និងវិធាន ៦០ នៃវិធានផ្ទៃក្នុង។

ផ្លូវភេទ (ដែលបានប្រព្រឹត្តឡើងក្រៅបរិបទនៃការរៀបការដោយបង្ខំ) ដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខនេះ[23]។ ត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការរំលោភផ្លូវភេទបានកើតមាននៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងចំណោមកន្លែងផ្សេងៗដែលមានហេតុការណ៍នេះ[24]។ ទោះបីយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបការដោយបង្ខំ មិនអាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានប្រើប្រាស់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម[25]។ ដីកាដំណោះស្រាយក៏មិនបានចោទប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការរំលោភផ្លូវភេទនៅមន្ទីរសន្តិសុខក្រាំងតាចាន់ដោយផ្អែកទៅលើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែរ[26]។

១២. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ភាគីមានឱកាសច្រើនក្នុងការលើកបង្ហាញ និង ប្រាប់ទៅដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីទាំងនេះ អំពីភាពមិនស៊ីសង្វាក់រវាងសក្ខីកម្ម និង ចម្លើយកាលពីពេលមុនៗរបស់ពួកគេ ដែលត្រូវបានចោទប្រកាន់ ពាក់ព័ន្ធនឹងគ្រប់បញ្ហាទាំងអស់ដែលបានលើកឡើងនៅក្នុងសំណើសុំ។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង សូត្រ សាំង និង សាក្សី ស្រី ថន ត្រូវបានសួរដេញដោលយ៉ាងច្រើននៅចំពោះមុខអង្គជំនុំជម្រះចំពោះចម្លើយ និង ការថ្លែងផ្សេងៗរបស់ពួកគេ[27]។ ហេតុដូច្នេះ ដំណើរការនៃការសួរដេញដោលក្នុងតុលាការចំពោះបុគ្គលនីមួយៗទាំងនេះ

---

[23] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ឯកសារ E306 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៣។

[24] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤២៦។

[25] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤២៦។

[26] *សូមមើល* សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៥៤៥ (ការរៀបចំផែនការ) កថាខណ្ឌ ១៥៤៨ (ការញុះញង់) កថាខណ្ឌ ១៥៥១ (ការជួយ និងជំរុញ) កថាខណ្ឌ ១៥៥៤ (ការបញ្ជា) កថាខណ្ឌ ១៥៥៩ (ការទទួលខុសត្រូវរបស់ថ្នាក់លើ)។

[27] អង្គជំនុំជម្រះយោងទៅការដកស្រង់ខ្លះពីប្រតិចារឹកនៃសក្ខីកម្មរបស់ សយ សែន ស្រី ថន និង សូត្រ សាំង ដែលពួកគេត្រូវបានដេញដោលទៅលើបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងសំណើសុំ៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន) ទំព័រ ២៩-៣០, ៧០-៧២។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៥ (សូត្រ សាំង) ទំព័រ ១៤-១៥, ៤៩, ៥៥។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សយ សែន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សូត្រ សាំង) ទំព័រ ៦-៧, ៩-១០, ១២-១៣, ៤១-៤៣។

បានការពារសិទ្ធិរបស់ជនជាប់ចោទគ្រប់គ្រាន់ហើយ។ ភស្តុតាងដែលត្រូវបានដេញដោលនៅក្នុងតុលាការ រួមទាំងភាពផ្ទុយគ្នានៃសក្ខីកម្មនានា នឹងត្រូវវាយតម្លៃដោយអង្គជំនុំជម្រះនៅដំណាក់កាលសមស្របមួយ។ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះសាលាដំបូងយល់ថា មិនចាំបាច់មានការតទល់គ្នារវាងបុគ្គលទាំងនេះឡើយ។

១៣. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សំណើនេះត្រូវបានដាក់កៀកពេលបញ្ចប់ការបង្ហាញភស្តុតាងនៅក្នុងវគ្គសវនាការពាក់ព័ន្ធនឹងស្រុកត្រាំកក់។ យ៉ាងណាក៏ដោយ ភាគីបានដឹងច្រើនពីលក្ខណៈ និង ខ្លឹមសារនៃការចោទប្រកាន់ទាំងនោះ ដែលជាកម្មវត្ថុនៃសំណើនេះ ចាប់តាំងពីដំណាក់កាលមុនជំនុំជម្រះមកម្ល៉េះ។ បុគ្គលដែលពាក់ព័ន្ធទាំងអស់សុទ្ធតែត្រូវបានស្តាប់ចម្លើយរួចហើយដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងដំណាក់កាលស៊ើបអង្កេតនៃសំណុំរឿង ០០២។ ហេតុដូច្នេះ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សយ សែន និង សូត្រ សាំង គឺជាផ្នែកមួយនៃសំណុំរឿងស៊ើបអង្កេតនេះ[28]។ ហេតុដូច្នេះ ការផ្តល់សក្ខីកម្មរបស់ សយ សែន មិនបានធ្វើឱ្យអង្គជំនុំជម្រះ និង ភាគីផ្សេងទៀត ដឹងអំពីការចោទប្រកាន់នេះជាលើកដំបូងឡើយ ប៉ុន្តែគ្រាន់តែឱ្យពួកគាត់ឡើងមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ជាជាងការសរសេរជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ ជាចុងក្រោយ អង្គជំនុំជម្រះក៏ពិចារណាទៅលើកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឱ្យមានការជំនុំជម្រះក្តីដោយឆាប់រហ័ស។ ពាក់ព័ន្ធនឹងចំណុចនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីទាំងនេះ សាជាថ្មីម្តងទៀត នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនេះនឹងតម្រូវឱ្យសាកសួរអំពីលទ្ធភាពរបស់ពួកគេក្នុងការចូលរួមក្នុងសវនាការ ការរៀបចំដឹកជញ្ជូនពួកគេទាំងមក និង ចាកចេញពី អ.វ.ត.ក ទៅវិញ ព្រមទាំងការ

---

[28] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ សែន៖ ឯកសារ E3/5129 ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ឯកសារ E3/5214 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៨ និង បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលភ្ជាប់ជាឧសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សយ សែន ឯកសារ E3/4846 ដែលត្រូវបានដាក់នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ផន៖ ឯកសារ D125/129 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ និង ឯកសារ D232/93 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ សាំង៖ ឯកសារ D40/21 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សូត្រ សាំង ឯកសារ D22/88 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩។

ធានានូវការការពារសុវត្ថិភាពដល់ពួកគេ។ ការអនុវត្តវិធានការទាំងនេះនឹងត្រូវការពេលវេលាជាច្រើន។ ការអនុវត្តវិធានការទាំងនេះត្រូវតែមានតុល្យភាពជាមួយនឹងផលប្រយោជន៍មួយចំនួនពីការតទល់ដែលអាចមាន ប្រសិនបើការតទល់នេះអាចផ្តល់ប្រយោជន៍។

១៤. អាស្រ័យដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា ការតទល់គ្នានឹងមិនរួមចំណែកបន្ថែមទៀតចំពោះការវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បានរបស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយក៏មិនជួយដល់ការបញ្ជាក់ការពិតដែរ។ ហេតុដូច្នេះ អនុលោមតាមវិធាន ៨៧(៣) និង វិធាន ៩១ នៃវិធានផ្ទៃក្នុង និង ផ្អែកទៅលើកាលៈទេសៈបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើនេះ។

១៥. ចំពោះសំណើសុំឯកសារថតសម្លេងការស្តាប់ចម្លើយរបស់ សយ សែន នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារថតសម្លេងការស្តាប់ចម្លើយ E3/5129 និង E3/5214 មាននៅក្នុងកំណត់ត្រារបស់សំណុំរឿង ០០២/០២ រួចហើយ ដូច្នេះហើយ ភាគីអាចចូលទៅពិនិត្យមើលបាន អនុលោមតាមវិធាន ៥៥(៦) និង វិធាន ៨៦ នៃវិធានផ្ទៃក្នុង។ តែផ្ទុយទៅវិញ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ឯកសារថតសម្លេងការស្តាប់ចម្លើយ E3/5129 និង E3/5214 នេះ មិនមានអត្ថិភាពទេ[29]។

១៦. ផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឯកសារថតសម្លេងការស្តាប់ចម្លើយរបស់ សយ សែន លែងជាការចាំបាច់ហើយ។ ពាក់ព័ន្ធនឹងភាពមិនស៊ីសង្វាក់គ្នាដែលបានលើកឡើងរវាងចម្លើយរបស់ សយ សែន កាលពីពេលមុន និង ភស្តុតាងផ្ទាល់មាត់នៅក្នុងសវនាការ អង្គជំនុំជម្រះរម្លឹកថា ជាគោលការណ៍ទូទៅ ចំណុចនេះគួរត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះនៅពេលវាយតម្លៃអំពីតម្លៃនៃភស្តុតាង និង ទម្ងន់ដែលត្រូវផ្តល់ទៅឱ្យភស្តុតាងនោះ[30]។

---

[29] *សូមមើល* ការឆ្លើយឆ្លងអ៊ីមែលរវាងអង្គជំនុំជម្រះសាលាដំបូង និង ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E348/4.1។

[30] សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E/241/1) ឯកសារ E251 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២៨។

01105569



១៧. ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់អំពីការរៀបចំដែលត្រូវបានធ្វើឡើងដើម្បីផ្តល់ការធ្វើជាតំណាងផ្លូវច្បាប់ដោយឡែក[31] សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន និង សូត្រ សាំង ដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចមាន[32]។ ដោយពិចារណាទៅលើកាលៈទេសៈនានា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធានការដែលបានអនុវត្តដោះស្រាយបានយ៉ាងល្អចំពោះទំនាស់ផលប្រយោជន៍ដែលអាចមាន និង ធានាបានការធ្វើតំណាងផ្លូវច្បាប់ត្រឹមត្រូវសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ ស្របទៅតាមវិធាន ២១ និង វិធាន ២៣ ស្ទួនពីរ នៃវិធានផ្ទៃក្នុង។

**ដោយផ្អែកទៅលើសំអាងហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង សម្រេច៖**

**បដិសេធ** សំណើរបស់ ខៀវ សំផន សុំឱ្យកោះហៅ សយ សែន សូត្រ សាំង និង ស្រី ថន សាជាថ្មី និងស្តាប់ចម្លើយពួកគាត់នៅក្នុងពេលតែមួយ។

**បដិសេធ** សំណើរបស់ ខៀវ សំផន សុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយរបស់ សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយចាត់ទុកថាសំណើនេះលែងជាការចាំបាច់ទៀតហើយ។

ភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

[31] អ៊ីមែលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្ញើទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ E339/1។ អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅកាន់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ E339/2។ *សូមមើលផងដែរ* ការដកខ្លួនចេញពីការតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ សូត្រ សាំង (2-TCCP-304) និង សយ សែន (2-TCCP-271) ឯកសារ E339/3 និង ឯកសារ E339/4។

[32] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅកាន់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ E339។